## គម្រោង ការរៀនសូត្រពីប្រវត្តិសាស្ត្រ



# ប្រវត្តិការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

អង្គការយុវសន្តិភាព

# មាតិកា

ជំពូក១. ប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា
ជំពូក២. ប្រវត្តិការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង
២.១. ទីតាំងភូមិសាស្ត្រ និងលក្ខណៈពិសេសនៃព្រលានយន្តហោះ
២.២.ទីតាំងការដ្ឋានសាងសង់ព្រលានយន្តហោះនៅមុនសម័យខ្មែរក្រហម
២.៣. ទីតាំងការដ្ឋានសាងសង់ព្រលានយន្តហោះនៅអំឡុងសម័យខ្មែរក្រហម
២.៣.១. ដំណើរការនៃការសាងសង់
២.៣.២. ស្ថានភាពរស់នៅរបស់អ្នកធ្វើការនៅការដ្ឋានសាងសង់
២.៣.៣. រចនាសម្ព័ន្ធនៃការគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធនៅការដ្ឋាន
២.៣.៤. ទីតាំងឧក្រិដ្ឋកម្ម
២.៤. ទីតាំងការដ្ឋាននៅក្រោយរបបខ្មែរក្រហម
២.៤.១. សំណល់អាគារ និងសម្ភារៈ
២.៤.២. ការគ្រប់គ្រង់ និងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ

# ជំពូក១ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

បក្សកុម្មុយនីស្តឥណ្ឌូចិនត្រូវបានបង្កើតឡើងដោយ ហូ ជីមិញ នៅឆ្នាំ១៩៣០ ដើម្បីដេញអាណានិគមបារាំងចេញពីឥណ្ឌូចិន។ បក្សនេះប្រមូលផ្តុំចលនាកុម្មុយនីស្តដែលមកពីប្រទេសកម្ពុជា វៀតណាម និងឡាវ។ បន្ទាប់ពីជប៉ុនបានមកកាន់កាប់ឥណ្ឌូចិននៅឆ្នាំ១៩៤១ បក្សកុម្មុយនីស្តឥណ្ឌូចិនបានធ្វើការប្រែប្រួលទិសដៅរបស់ខ្លួនមួយចំនួន។ ដើម្បីឱ្យការតស៊ូរំដោះជាតិបានកាន់តែមានភាពធំទូលាយ ប្រទេសនីមួយៗត្រូវបង្កើតរណសិរ្សរបស់ខ្លួន។ នៅកម្ពុជាមានចលនាតស៊ូទាមទារឯករាជ្យពីបារាំងដែលគេហៅថារណសិរ្ស **"ខ្មែរឥស្សរៈ"** ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤២ ត្រូវបានបែងចែកជាបីក្រុមមានដូចជា ចលនារបស់លោក សឺង ង៉ុកមិញ ហៅអាចារ្យ អន មាន ជាអនិកជនវៀតណាមមានស្រុកកំណើតនៅខេត្តកំពត ដែលធ្លាប់បានបួសរៀននៅសំណាក់វត្ត សឺយកៀក នៅវាលវង់ប្រណាំងសេះជាវត្តយួន ប៉ុន្តែកាន់ពុទ្ធសាសនា នៅជិតវត្តសំពៅមាស ដែលមានការគាំទ្រដោយ វៀតមិញ នៅពីក្រោយ ហើយមានមូលដ្ឋាននៅខេត្តកំពត ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងបណ្តាខេត្តមួយចំនួនចាប់ជាមួយប្រទេសវៀតណាម។ ចំណែកឯចលនារបស់លោក សឺង ង៉ុកថាញ់ ជាខ្មែរកម្ពុជាក្រោមដែលមានមូលដ្ឋាននៅតាមភ្នំដងរែកក្នុងខេត្ត ឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តបាត់ដំបង ដែលមាននិន្នាការសេរីបានដឹកនាំមហាបាតុកម្មដេញបារាំងនៅខែកក្កដា ឆ្នាំ១៩៤២ ហើយដែលបានរត់ទៅប្រទេសជប៉ុននៅពេលដែលបារាំងចាប់អាចារ្យ ហែម ចៀវ លោក ប៊ុន ចាន់ម៉ុល និងអ្នកតស៊ូមួយចំនួនទៀតត្រូវបានដាក់គុកនៅកោះត្រឡាច។ ចលនាមួយទៀត គឺចលនារបស់អង្គម្ចាស់ នរោត្តម ចន្ទរង្សី ហើយមានមូលដ្ឋាននៅបន្ទាយច្បារមន ខេត្តកំពង់ស្ពឺ ដែលការពាររបបរាជានិយមជាពិសេសរាជ្យវង្សនរោត្តម។ នៅប្រទេសវៀតណាម និងកម្ពុជា អាចារ្យ អន មាន ហៅ សឺង ង៉ុកមិញ ចាប់ផ្តើមតួនាទីមួយដ៏សំខាន់តាំងពីឆ្នាំ ១៩៤៩មក។ នៅក្នុងមហាសន្និបាតទី១ នាថ្ងៃទី១១ដល់១៩ ខែកុម្ភៈ ឆ្នាំ ១៩៥០ បក្សកុម្មុយនីស្តឥណ្ឌូចិន(PCI)សម្រេចឲ្យប្រទេសនីមួយៗនៅឥណ្ឌូចិនបង្កើតកងទ័ពឯក-រាជ្យរបស់ខ្លួនផ្ទាល់។ ចំណែកនៅកម្ពុជាបានបង្កើតរណសិរ្សរួបរួមជាតិដែលមានលោក ទូត សាមុត ជាលេខា។ រណសិរ្សនេះបង្កើតភ្លេងជាតិមួយ និងទង់ជាតិដែលមានរូបអង្គរវត្ត

ពណ៌លឿងដែលមានកំពូលប្រាំលើផ្ទៃពណ៌ក្រហម។ ឆ្នាំ១៩៥១ គណបក្សឥណ្ឌូចិនត្រូវបានរំលាយ ហើយបានបែកជាបីសាខា គឺគណបក្សឡាវដុង ជាគណបក្សពលកររៀតណាម គណបក្សនេអូឡាវហាក្សានៅប្រទេសឡាវ និងគណបក្សប្រជាជនបដិវត្តន៍ខ្មែរនៅកម្ពុជា។ នៅស្រុកខ្មែរនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ក្រោយមហាសន្និបាតទី២នៃបក្សកុម្មុយនីស្តឥណ្ឌូចិន ខ្មែរមួយក្រុមបានបង្កើតគណបក្សកុម្មុយនីស្តមួយមានឈ្មោះថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ" (P.P.R.K)ដែលកាលនោះមានលោក សឺង ង៉ុកមិញជាប្រធាន និងលោក ទូ សាមុត ជាអនុប្រធាន និងលោក ស៊ីវ ហេង ជាលេខា។ ក្រោយសន្និសញ្ញាក្រុងហ្សឺណែវនៅថ្ងៃទី២០ ខែកក្កដា ១៩៥៤ ដែលតម្រូវឲ្យបារាំងដកកងទ័ពចេញពីបណ្តាប្រទេសនៅឥណ្ឌូចិន។ ទាំងប្រទេសវៀតណាម និងប្រទេសឡាវត្រូវបានបែងចែកជាពីរ។ ចំណែកឯកងទ័ពវៀតមិញដែលធ្លាប់មានវត្តមាននៅលើទឹកដីកម្ពុជាត្រូវដកចេញ។ ខណៈពេលនោះកងទ័ពវៀតមិញវាយលុកខេត្តរតនៈគីរី ដើម្បីបង្ខំអង្គប្រជុំឲ្យបែងចែកប្រទេសកម្ពុជា ប៉ុន្តែត្រូវទទួលបរាជ័យ។ តាមរយៈកិច្ចព្រមព្រៀងនៅ ហ្សឺណែវ យុទ្ធជនខ្មែរវៀតមិញ៥ពាន់ត្រូវសម្រេចចិត្តក្នុងការជ្រើសរើសផ្លូវមួយរវាងការភៀសខ្លួនទៅកាន់វៀតណាមខាងជើង ឬទម្លាក់អាវុធចុះចូលជាមួយកងទ័ពខេមរៈភូមិន្ទ។ ចំណែកលោក សឺង ង៉ុកមិញ និងមនុស្សជំនិតរបស់គាត់មួយចំនួនទៀតបានរត់ទៅហាណូយ ចាប់តាំងពេលនោះមកគាត់បានបាត់ខ្លួនរីឯគណបក្សប្រជាជនបដិវត្តន៍ត្រូវដឹកនាំដោយលោក ទូ សាមុត ជាប្រធាន និងលោក ស៊ីវ ហេង ជាអនុប្រធាន។ នៅថ្ងៃទី១១ ខែកញ្ញា ១៩៥៥ គណបក្សសង្គមរាស្ត្រនិយមបានឈ្នះសំឡេងឆ្នោតច្រើនលើសលុប ចំណែកឯគណបក្សប្រជាជនបដិវត្តន៍ខ្មែរទទួលបានសន្លឹកឆ្នោតត្រឹមតែ៤%។ ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវបក្សប្រជាជនបដិវត្តន៍ខ្មែរបានបែកចែកជាបីក្រុម។ ក្រុមទី១ដែលមាន សឺង ង៉ុកមិញ កែវ មន្នី មី ផូ និងរត្ន័ សាមឿន ព្រមទាំងប៉ែន សុវណ្ណ ជាមួយនឹងយុទ្ធជន២ពាន់៥រយនាក់ផងដែរបានត្រូវបញ្ជូនទៅទីក្រុងហាណូយប្រទេសវៀតណាមក្រោមការត្រួតពិនិត្យរបស់គណកម្មាធិការត្រួតពិនិត្យអន្តរជាតិ។ ក្រុមទី២ដែលមានជាអាទិ៍ ទូ សាមុត សៀវ ហេង នួន ជា សោ ភឹម ណី ប៉ាន់ ជាដើមបាននាំគ្នាគេចខ្លួនទៅបង្កើតចលនាលួចលាក់មួយទៀតនៅក្នុងទឹកដីកម្ពុជា។ អ្នកទាំងនោះហើយដែលជាស្នូលដំបូងបង្អស់នៃចលនាខ្មែរក្រហម។ ក្រុមទី៣ដែលមាន នង សួង កែវ

មាស និងប៉ែន យុទ្ធ ជាដើមបាននាំគ្នាបង្កើតគណបក្សនយោបាយត្រឹមត្រូវស្របច្បាប់មួយ ដែលមានឈ្មោះហៅថា"គណបក្សប្រជាជន"។ នៅឆ្នាំ១៩៥៨ សៀវ ហេង ដែលជាអគ្គលេខាបក្សប្រជាជនបដិវត្តន៍កម្ពុជាបានចុះចូលដោយសម្ងាត់ជាមួយសម្តេចនរោត្តមសីហនុ។ សៀវ ហេង ក៏បានក្លាយជារនុកក្នុងរបស់ចលនាសង្គមរាស្រ្តនិយមដោយនៅតែបន្តកាន់តំណែងកំពូលរបស់បក្សប្រជាជនបដិត្តន៍កម្ពុជាដដែរ រហូតដល់ឆ្នាំ១៩៥៩ត្រូវបានដកបេក្ខភាពចេញពីបក្ស។ សៀវ ហេង បានផ្តល់ព័ត៌មានសម្ងាត់ជាច្រើនទាក់ទងនឹងចលនាកុម្មុយនីស្តខ្មែរដែលជួយឲ្យកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលធ្វើការបំបែកសម្បុកសម្ងាត់របស់ពួកកុម្មុយនិស្ត។ នៅចន្លោះថ្ងៃទី២៨ និង៣០ ខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តខ្មែរបានបើកមហាសន្និបាតជាសម្ងាត់មួយដែលប្រព្រឹត្តទៅនៅក្នុងផ្ទះមួយដែលជាផ្ទះរបស់លោក អុក សាគុណ ជិតស្ថានីយរថភ្លើងទីក្រុងភ្នំពេញ ហើយបានប្តូរឈ្មោះបក្សប្រជាជនបដិវត្តខ្មែរមកជាបក្សពលករខ្មែរវិញ ដែលមាន លោក ទូសាមុត ជាលេខាបក្ស និងលោកនួន ជា ជាអនុលេខាបក្ស។ ក្រោយមកលោក ទូ សាមុត បានបាត់ខ្លួននៅពេលលោកជិះកង់ទៅទិញកាហ្វេនៅផ្ទុំទួលស្វាយព្រៃនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៦២។ នៅថ្ងៃ ២០-២១ ខែកុម្ភៈ ឆ្នាំ១៩៦៣ នៅក្នុងឱកាសមហាសន្និបាត «បក្សពលករខ្មែរ» សាឡុត ស ដែលក្រោយមកមានឈ្មោះថា ប៉ុល ពត ត្រូវបានតែងតាំងជាអគ្គលេខាធិការបក្សដោយគ្មានកាបោះឆ្នោតជ្រើសតាំងអ្វីទាំងអស់ ហើយរំលងលោក នួន ជា ដែលជាអនុលេខា និងជាប្អូនសាច់ថ្លៃរបស់លោក ស៊ីវ ហេង ដោយសារតែគាត់ជាប់ខ្សែក្បត់។ ក្រោយមកបានចាកចេញពីភ្នំពេញមកតាំងទីលំនៅនាកន្លែងសម្ងាត់មួយនៅជិតស្រុកក្រូចឆ្មាក្នុងខេត្ត កំពង់ចាម ដែលមានឈ្មោះថា «ការិយាល័យលេខ១០០»។ នៅចន្លោះឆ្នាំ ១៩៦៤-១៩៦៥ ប៉ុល ពត បានធ្វើទស្សនកិច្ចថ្មើរជើងតាមផ្លូវលំហូជីមិញ ដោយឆ្លងកាត់ប្រទេសវៀតណាម និងប្រទេសចិនឆ្ពោះទៅកាន់កូរ៉េខាងជើង។ ក្រោយពីបានធ្វើទស្សនះកិច្ចរួចនៅឆ្នាំ១៩៦៦ ប៉ុល ពត បានបើកមហាសន្និបាតផ្ទៃក្នុងបក្ស ដើម្បីប្តូរឈ្មោះ បក្សពលករខ្មែរដែលមានឈ្មោះ ដូចបក្សពលករវៀតណាម មកជាបក្សកុម្មុនីស្តកម្ពុជា និងបានប្តូរទីតាំងសម្ងាត់មកនៅខេត្តរតនៈគីរី ដែលមានឈ្មោះថា «ការិយាល័យលេខ១០២»។ នៅឆ្នាំ១៩៦៧ ដោយមានការផ្ទុះឡើងនូវបដិវត្តវប្បធម៌នៅប្រទេសចិន ហើយនៅក្នុងស្រុកខ្មែរមានកាបះបោរ

របស់និស្សិតខ្មែរដែលអត់មានការងារធ្វើ ហើយមិនព្រមទៅធ្វើស្រែវិញ បានបណ្ដោយខ្លួនជឿពាក្យញុះញង់របស់ពួកកុម្មុយនីស្ដ និងមានបញ្ហានៅសំឡូត ដែលបណ្ដាលមកពីការប្លន់ដណ្ដើមដីពីប្រជាពលរដ្ឋ និងការបញ្ចុះតម្លៃស្រូវដែលរដ្ឋាភិបាលបានដើរប្រមូលទិញពីប្រជាកសិករ។ នៅពេលនោះសម្ដេច នរោត្តម សីហនុ មានការខ្ចាល់យ៉ាងខ្លាំងហើយបានដាក់ឈ្មោះឱ្យក្រុមនេះថា «ខ្មែរក្រហម» តាំងពីពេលនោះមក។ បន្ទាប់មករដ្ឋមន្ត្រីខាងឆ្វេងនិយមបីរូប គឺលោក ខៀវ សំផន លោក ហូ នឹម និងលោក ហូ យន់ ត្រូវបានសម្ដេច នរោត្តម សីហនុ ចោទប្រកាន់ថា បានផ្សំគំនិតនៅក្នុងព្រឹត្តិការណ៍នៅសំឡូតដែលបានបះបោរប្រឆាំងជាមួយរដ្ឋាភិបាល។ ចាប់ពីពេលនោះមកពួកកុម្មុយនីស្ដនេះបានចាប់ផ្ដើមធ្វើការតស៊ូដោយប្រដាប់អាវុធប្រឆាំងនឹងសម្ដេច សីហនុដោយធ្វើការវាយឆ្មក់តាំងពីមូលដ្ឋានដែលគេមាននៅក្នុងភូមិភាគឦសាន និងពាយ័ព្យ។ នៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ មានការធ្វើរដ្ឋប្រហារទម្លាក់សម្ដេច នរោត្តម សីហនុ ពីប្រមុខរដ្ឋកម្ពុជា ដោយលោក សេនាប្រមុខលន់ នល់ និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ នៅពេលព្រះអង្គកំពុងបំពេញទស្សនៈកិច្ចនៅក្រៅប្រទេស។ នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧០ សម្ដេច នរោត្តម សីហនុ បានអំពាវនាវពីទីក្រុងប៉េកាំង ដោយបានបង្កើតរណសិរ្សរួបរួមជាតិ ហើយឱ្យជនរួមជាតិខ្មែរដែលស្រឡាញ់ និងស្វាមីភក្ដិ៍ចំពោះព្រះអង្គរត់ចូលព្រៃម៉ាគីធ្វើការតស៊ូ ដើម្បីផ្ដួលរំលំរបបក្រុងភ្នំពេញ។ អតីតកម្មាភិបាលខ្មែរវៀតមិញដែលបង្កប់ខ្លួននៅប្រទេស ចាប់ផ្ដើមធ្វើសង្គ្រាមវិញ។ រីឯខ្មែរវៀតមិញដែលចេញទៅហាណូយនៅឆ្នាំ១៩៥៤ ក៏វិលត្រឡប់មកប្រទេសកម្ពុជាវិញតាមផ្លូវលំហូជីមិញ។ នៅចុងឆ្នាំ១៩៧០ កងទ័ពកុម្មុយនីស្ដវៀតណាមប្រគល់កងទ័ពទាំងនោះទៅឱ្យពួកខ្មែរក្រហមដែលជាបញ្ញាវ័ន្តត្រឡប់ពីប្រទេសបារាំង ហើយរត់ចូលព្រៃតាំងពីឆ្នាំ១៩៦៣ មក មានចំនួន ៣.០០០នាក់ នៅពេលមានការអំពាវនាវពីសម្ដេចសីហនុពួកនេះបានកើនឡើងរហូតដល់ចំនួន៣០.០០០នាក់ មិនដល់មួយអាទិត្យផង ដោយពួកខ្មែរក្រហមបានយកប្រជាប្រិយភាពរបស់សម្ដេចសីហនុ ដើម្បីឱ្យប្រជាជនចូលរួមក្នុងចលនាបដិវត្តរបស់ពួកគេ ។ រីឯប្រជាជនខ្មែរដែលគាំទ្រសម្ដេចសីហនុក៏បង្កើត "**កងទ័ពរំដោះ**" ស្ថិតក្រោមការគ្រប់គ្រងរបស់ពួកកុម្មុយនីស្ដ។ តាំងពីពេលនោះមក ក្រុមខ្មែរក្រហមចាប់ផ្ដើមរីកធំធាត់ ហើយបានបង្កអសន្តិសុខ និងបានកាន់កាប់តំបន់ស្ទើរតែមួយភាគប្រាំនៃទឹកដីកម្ពុជា។

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៣ រដ្ឋាភិបាលអាមេរិក និងវៀតណាមខាងជើង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅ ឡា សែល សាំង គ្លូ ( La Celle St Cloud ) ដើម្បីបញ្ចប់សង្គ្រាមវៀតណាម ហើយកិច្ចព្រមព្រៀងនេះបានតម្រូវឱ្យដកកងទ័ពវៀតកុងដែលបានមកតាំងទីរស់នៅលើទឹកដីកម្ពុជា ក្នុងគោលបំណងធ្វើជាមូលដ្ឋានក្នុងការវាយដណ្ដើមយកវៀតណាមខាងត្បូង។ ក្រោយពីមានបទឈប់បាញ់គ្នារវាងវៀតណាមខាងជើង និងអាមេរិក ពួកខ្មែរដែលបានបញ្ជូនមកពីវៀតណាមខាងជើងវិញ ត្រូវបានគេសម្លាប់ចោលដោយលួចលាក់ ជាពិសេស លោក សឺង ង៉ុកមិញ ត្រូវបានគេបំពុលស្លាប់នៅឆ្នាំ ១៩៧២។ ពួកកុម្មុយនីស្តខ្មែរក៏បានពិសោធន៍ធ្វើកម្មវិធីសហករណ៍នីយកម្មនៅក្នុងតំបន់គេគ្រប់គ្រង់ ប៉ុន្តែត្រូវបានបរាជ័យហើយនៅដើមឆ្នាំ១៩៧៣ នៅក្នុងពេលដែលអាមេរិកមានយុទ្ធនាការទម្លាក់គ្រាប់បែកបក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្ដើមអនុវត្តកម្មវិធីសហករណ៍ដោយបង្ខិតបង្ខំនៅក្នុងតំបន់មួយចំនួន។ ជាបន្តបន្ទាប់ ផ្លូវសេដ្ឋកិច្ចសំខាន់ៗ ត្រូវកាត់ផ្ដាច់ទាំងស្រុងនៅឆ្នាំ១៩៧៣។ ទីរួមខេត្តនៅឆ្ងាយពីទីក្រុងទាំងអស់ ត្រូវឡោមព័ទ្ធជាប់ដោយពួករំដោះនៅឆ្នាំ១៩៧៣ផងដែរ។ ពួកកុម្មុយនីស្តបានដាក់មីននៅគ្រប់ច្រកចូលតាមផ្លូវទឹកមកកាន់ទីក្រុងភ្នំពេញដើម្បីរាំងការដឹកជញ្ជូនអង្ករ និងគ្រាប់រំសេវមិនឱ្យចូលមករាជធានីបាន។ មកដល់ឆ្នាំ ១៩៧៤ ពួកគេបានកំណត់ថ្ងៃចុងក្រោយរបស់សាធារណរដ្ឋខ្មែរជាស្រេច ដូចមានសេចក្ដីក្នុងបទចំរៀងជាច្រើនបទ ដែលគេបានហាត់រៀនច្រៀង និងថតទុកចាក់ផ្សាយនៅថ្ងៃជ័យជម្នះ១៧មេសា១៩៧៥ ។ ដើម្បីវាយដណ្ដើមទីក្រុងភ្នំពេញ ពួកខ្មែរក្រហមបានចាប់ផ្ដើមធ្វើការវាយលុកជាបន្តបន្ទាប់ចំនួន៣លើកនៅឆ្នាំ១៩៧៣ ១៩៧៤ និងនៅឆ្នាំ ១៩៧៥ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃអវសាននៃរបបសាធារណរដ្ឋខ្មែរ នៅពេលដែលកងទ័ពខ្មែរក្រហមវាយដណ្ដើមកាន់កាប់បានទីក្រុងភ្នំពេញនៅវេលាម៉ោង៩:៣០នាទីព្រឹកដែលជាពេលដែលខ្មែរក្រហមឈានជើងចូលមកកាន់អំណាច ។

# ជំពូក២ ប្រវត្តិការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង

## ២.១. ទីតាំងភូមិសាស្ត្រ និងលក្ខណៈពិសេសនៃព្រលានយន្តហោះកំពង់ឆ្នាំង

### ក. ទីតាំងភូមិសាស្ត្រ

ព្រលានយន្តហោះកំពង់ឆ្នាំងស្ថិតនៅតំបន់ខ្ពង់រាប នៅទិសខាងត្បូងឈាងខាងកើតជាតំបន់ភ្នំ ហើយភ្នំដែលនៅជិតព្រលានយន្តហោះបំផុតគឺភ្នំតាបាំងមានកំពស់ ២៦៧ម៉ែត្រ និងខាងលិចមានកូនស្ទឹងមួយដែលហូរចាក់ទៅក្នុងបឹងទន្លេសាប។ ព្រលានយន្តហោះនេះស្ថិតនៅចន្លោះខ្សែស្របតាមរយៈបណ្តោយ១០៤$^{0}$ ១០′ដល់១០៤$^{0}$ ៥៥′ និងរយៈទទឹង១១$^{0}$ ៤៥′ ដល់១២$^{0}$ និង៤៥′។ ចំពោះសីតុណ្ហភាពនៅតំបន់នោះជាមធ្យម ៤០$^{0}$C នៅពេលថ្ងៃនិងពេលយប់ ២៣$^{0}$C នៅពេលយប់ គឺមានការប្រែប្រួលខ្លាំង។[1]

ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ស្ថិតនៅលើឃុំចំនួនបីនៃស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង។ ឃុំទាំងបីនោះរួមមាន ឃុំពង្រ ឃុំបន្ទាយព្រាល និងឃុំក្រាំងលាវ ហើយផ្ទៃដីព្រលានទាំងមូលលាតសន្ធឹងនៅលើភូមិចំនួនប្រាំ គឺភូមិប៉ាតឡាង ភូមិព្រៃបៀត ភូមិផ្លូវគោ ភូមិត្រពាំងធំ និងភូមិជ្រេស។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ការដ្ឋានសាងសង់ព្រលានយន្តហោះនេះស្ថិតនៅស្រុក២០ តំបន់៣១ នៃភូមិភាគបស្ចឹម(ភូមិភាគ៤១)។ លោកវិរៈសេនីយ៍ឯក ហ៊ីង ស៊ុនតារា មេបញ្ជាការរង ទទួលបន្ទុកសុរិយោដីប្រចាំការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំងបច្ចុប្បន្ន បានឱ្យដឹងថា ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងមានផ្ទៃដីសរុប១៤១៥ហិចតា និងមានបរិវេណជុំវិញព្រលានប្រមាណ១៨គីឡូម៉ែត្រ[2]។ គាត់បានបន្ថែមទៀតថាព្រលានយន្តហោះនេះមានព្រំប្រទល់ ខាងជើងប្រមាណ៥០%ជាប់ឃុំពង្រ ខាងកើតប្រមាណ៧០%ជាប់

[1] បញ្ជាការដ្ឋានកងទ័ពជើងអាកាស(មូលដ្ឋានទ័ពអាកាសកំពង់ឆ្នាំង). ប្រវត្តិសង្ខេបនៃព្រលានយន្តហោះកំពង់ឆ្នាំង

[2] បញ្ជាការដ្ឋានកងទ័ពជើងអាកាស(មូលដ្ឋានទ័ពអាកាសកំពង់ឆ្នាំង). ប្រវត្តិសង្ខេបនៃព្រលានយន្តហោះកំពង់ឆ្នាំង

ឃុំពង្រ និង៣០% ជាប់ឃុំក្រាំងលាវ ខាងត្បូង១០០% និងខាងលិច២០% ជាប់ឃុំក្រាំងលាវ ខាងលិចប្រមាណ៨០% និងខាងជើងប្រមាណ៥០%ជាប់ឃុំបន្ទាយព្រាល។ ព្រលានយន្តហោះកំពង់ឆ្នាំងមានចម្ងាយ១៣គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ឆ្នាំងតាមបណ្តោយផ្លូវជាតិលេខ៥ ដោយធ្វើដំណើរប្រមាណ ៨គីឡូម៉ែត្រពីទីរួមខេត្តនោះយើងនឹងឃើញផ្លូវបេតុងបែកចេញពីផ្លូវជាតិនៅខាងឆ្វេងដៃ ចូលតាមផ្លូវបេតុងនោះចម្ងាយប្រមាណ៥គីឡូម៉ែត្រនឹងទៅដល់ទីតាំងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។

**ខ. លក្ខណៈពិសេសនៃព្រលានយន្តហោះកំពង់ឆ្នាំង**

ខេត្តកំពង់ឆ្នាំងមានលក្ខណៈពិសេសជាច្រើន ដែលធ្វើឲ្យទីតាំងភូមិសាស្ត្រមួយនេះត្រូវបានខ្មែរក្រហមជ្រើសរើសក្នុងការសាងសង់ព្រលានយន្តហោះ។ មុនពេលដែលខ្មែរក្រហមសម្រេចជ្រើសរើសទីតាំងមួយនេះ គេបានសិក្សាយ៉ាងល្អិតល្អន់អំពីទីតាំងភូមិសាស្ត្រនៃខេត្តកំពង់ឆ្នាំង។ ការសិក្សាទាំងនោះផ្អែកទៅលើចំនុចសំខាន់ៗចំនួនបីចំនុច។ ចំនុចទីមួយដែលធ្វើឲ្យខ្មែរក្រហមជ្រើសរើសខេត្តមួយនេះក្នុងការសាងសង់ព្រលានយន្តហោះគឺ ស្ថិតនៅចំកណ្តាលនៃប្រទេសកម្ពុជាដែលជាទីតាំងឈរជើងសំរាប់វិស័យយោធា[3]។ ខេត្តកំពង់ឆ្នាំងជាតំបន់មួយដែលស្ថិតនៅជិតព្រំដែនប្រទេសវៀតណាម ដែលខ្មែរក្រហមមិនទុកចិត្ត និងធ្វើអោយមានភាពងាយស្រួលក្នុងការឃ្លោមមើលរាល់សកម្មភាពរបស់ពួកសត្រូវ ដើម្បីប្រើយុត្តិសាស្ត្រទប់ទល់នឹងព្រឹត្តិការណ៍ដែលបានកើតឡើងទាន់ពេលវេលា ដែលជាឱកាសសម្រាប់ការពារខ្លួន។ ជាការពិតណាស់ថាព្រលានយន្តហោះមួយនេះសាងសង់ឡើងក្នុងគោលបំណងបម្រើដល់វិស័យយោធា ដូច្នេះចំនុចកណ្តាលនៃប្រទេស ជាកត្តាអំណោយផលយ៉ាងមានសារៈសំខាន់ក្នុងការតាំងទីមូលដ្ឋានទ័ពអាកាសសម្រាប់ការពារផ្ទៃប្រទេសទាំងមូល។ ចំនុចទីពីរ ភ្នំដែលស្ថិតនៅក្បែរការដ្ឋានព្រលាន គឺជាកត្តាអំណោយផលសម្រាប់ការការពារខ្លួន។ នៅក្នុងវិស័យយោធា ភ្នំគឺជាចំនុចយុទ្ធសាស្ត្រមួយ សម្រាប់ការពារខ្លួនពីសត្រូវនៅពេលដែលសត្រូវវាយលុកមកលើមូលដ្ឋានទ័ពរបស់ខ្លួនជាយថាហេតុ។ ដោយសារមានភ្នំជារបាំងការពារមូលដ្ឋានទ័ព ដែលស្ថិតនៅក្បែរជើងភ្នំ ធ្វើឲ្យសត្រូវមានការលំបាកក្នុងការវាយ

[3] បញ្ជាការដ្ឋានកងទ័ពជើងអាកាស(មូលដ្ឋានទព័អាកាសកំពង់ឆ្នាំង). ប្រវត្តិសង្ខេបនៃព្រលានយន្តហោះកំពង់ឆ្នាំង

លុកឲ្យចំគោលដៅទៅលើទីតាំងសំខាន់ៗ ដូចជាទីតាំងសម្រាប់ផ្ទុកអាវុធ និងបន្ទាយជាដើម ។ ខ្មែរក្រហមបានយល់ច្បាស់ពីទីតាំងយុទ្ធសាស្ត្រមួយនេះ។ លើសពីនេះទៅទៀត ក្នុងការសាងសង់សំណង់ធំៗដូចជាព្រលានយន្តហោះ គេត្រូវការយ៉ាងចាំបាច់នូវថ្មភ្នំជាច្រើនលានតោនសម្រាប់ការសាងសង់។ ដូច្នេះវាមានភាពងាយស្រួលក្នុងការដឹកជញ្ជូនថ្មពីភ្នំមកកាន់ការដ្ឋាន ដោយប្រើប្រាស់មធ្យោបាយងាយស្រួលជាងដឹកជញ្ជូនថ្មពីទីកន្លែងឆ្ងាយៗ។ ចំនុចពិសេសទីបីគឺ កត្តាផ្ទៃដី និងអាកាសធាតុក៏ជាកត្តាអំណោយផលមួយផងដែរ។ ផ្ទៃដីនៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ជាតំបន់ខ្ពង់រាប គេចផុតពីការលេចទឹកជំនន់នៅរដូវវស្សា និងការដក់ទឹកជាដើម។ នៅរដូវប្រាំងថ្វីត្បិតតែមិនសូវមានភ្លៀងគ្រប់គ្រាន់ក៏តំបន់មួយនេះ នៅតែមានទឹកសម្រាប់ផ្គត់ផ្គង់ទីតាំងព្រលាន។ ប្រភពទឹកដ៏សំខាន់ដែលស្ថិតនៅក្បែរទីតាំងព្រលានគឺទន្លេសាបដែលមិនត្រឹមតែផ្តល់សម្រាប់វិស័យកសិកម្មប៉ុណ្ណោះទេ តែក៏សម្រាប់វិស័យយោធាផងដែរ។

**២.២. ទីតាំងការដ្ឋានសាងសង់មុនសម័យខ្មែរក្រហម**

ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង រួមផ្សំពីឃុំចំនួនបីមាន ឃុំពង្រ ឃុំក្រាំងលាវ និងឃុំបន្ទាយព្រាល ដែលភាគច្រើនជាវាលស្រែ និងភូមិអ្នកស្រុក។ នៅមុនឆ្នាំ១៩៧៥ តំបន់នេះធ្លាប់ជាសមរភូមិដ៏ក្តៅគគុកនៃការបង្ហូរឈាមគ្នារវាងកងទ័ពព្រៃរបស់បក្សកុម្មុយនិស្តកម្ពុជា និងកងទ័ពរបស់រដ្ឋាភិបាល លន់ នល់។

ក្រោយព្រឹត្តិការណ៍ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ចលនាតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជាកើនឡើងយ៉ាងឆាប់រហ័សដោយសារតែព្រះបាទ នរោត្តមសីហនុ អំពាវនាវឱ្យប្រជាជនដែលគាំទ្រព្រះអង្គរត់ចូលព្រៃម៉ាគី ដើម្បីរួមកម្លាំងជាមួយខ្មែរក្រហមប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់។ បន្ទាប់ពីការអំពាវនាវរបស់សម្តេចសីហនុ មានប្រជាជនជាច្រើនបានចូលរួមប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់។ នៅតាមទីជនបទមួយចំនួន ត្រូវបានរំដោះដោយជោគជ័យ និងគ្រប់គ្រងដោយកម្លាំងខ្មែរក្រហម។ ចលនាតស៊ូនេះបានរីកសាយភាយស្ទើរពាស

ពេញផ្ទៃប្រទេស លើកលែងទីក្រុងនិងទីប្រជុំជនមួយចំនួន។[4] យ៉ាងណាមិញ នៅក្នុងខេត្តកំពង់ឆ្នាំង មិនត្រូវបានរំដោះដោយជោគជ័យពីកម្លាំងខ្មែរក្រហមនោះទេ តែវាជាតំបន់ដែលមានភាពប្រទាញប្រទង់គ្នា ដោយមានការប្រយុទ្ធរវាងទ័ពខ្មែរក្រហម និងទ័ពសាធារណរដ្ឋខ្មែរ រហូតដល់ជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមគ្រប់គ្រងបានទាំងស្រុង។[5]

## ២.៣. ទីតាំងការដ្ឋានសាងសងក្នុងសម័យខ្មែរក្រហម

### ២.៣.១. ដំណើរការ និងបច្ចេកទេសនៃការសាងសង់

ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងកើតចេញពីការត្រួតពិនិត្យ និងពិភាក្សាដោយក្រុមគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ដែលមានមេដឹកនាំជាន់ខ្ពស់ជាច្រើនបានចូលរួម។ នៅក្នុងអង្គប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជានាដើមឆ្នាំ១៩៧៦ បានសម្រេចជ្រើសរើសខេត្តកំពង់ឆ្នាំងជាទីតាំងមួយសម្រាប់ធ្វើការសាងសង់ព្រលានយន្តហោះថ្មីមួយ ហើយក្រោយមកទើបគេដឹងថា ជាទីតាំងព្រលានយន្តហោះសម្រាប់បម្រើឱ្យវិស័យយោធា។ ព្រលានយន្តហោះនេះត្រូវបានប្រកាសជាផ្លូវការនៅក្នុងអង្គប្រជុំក្រោយមួយទៀតក្នុងថ្ងៃទី ១៩ ដល់ថ្ងៃទី២១ ខែមេសា ១៩៧៦ ហើយបានចាប់ផ្តើមសាងសង់ឡើងនៅក្នុងឆ្នាំ១៩៧៦ និងត្រូវបានបញ្ចប់ទៅវិញទាំងមិនទាន់រួចរាល់នាដើមខែមករា ឆ្នាំ ១៩៧៩។[6]

នៅក្នុងការដ្ឋានកសាងព្រលានយន្តហោះនេះ គ្រប់គ្រងដោយកងពលមួយក្រុមដែលគេស្គាល់ថាជាកងពល៥០២។ កងពលនេះត្រូវបានបង្កើតឡើងនៅក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ដែលរាប់បញ្ចូលទាំងកងពលដែលធ្លាប់មានពីមុនមក។ កងពលនេះមានតួនាទីធ្វើការគ្រប់គ្រង និងត្រួតពិនិត្យទៅលើកងទ័ពអាកាសរបស់បក្ស ជាពិសេស

---

[4] ឌី ខាំបូលី, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩),លើកទី២ ២០១១,មជ្ឈមណ្ឌលឯកសារកម្ពុជា

[5] បទសម្ភាសន៍, សំ យ៉ុម ប្រជាជនមូលដ្ឋានៅភូមិក្រាំងលាវនាសម័យខ្មែរក្រហម, រសៀលថ្ងៃទី ១៦ សីហា ២០១៧

[6] អ.វ.ត.ក, *សុំណុំរឿង០០២,* ១៩កញ្ញា២០០៧-ECCC-OCIJ, លេខ/No: D427,ទំព័រ១២៦

ទៅលើការដ្ឋានសាងសង់ព្រលានយន្តហោះ ហើយរាយការណ៍ដោយផ្ទាល់ទៅ សេនាធិការដ្ឋាន និងអគ្គសេនាធិការដ្ឋាននៃក្រសួងការពារជាតិ។ ពុំមាននរណាម្នាក់ដឹងថាមេដឹកនាំរបស់កងពល៥០២ ឈ្មោះអ្វីទេ ក៏ប៉ុន្តែមានគេដឹងថាអនុប្រធានដែលប្រចាំការនៅទីនោះផ្ទាល់ឈ្មោះ ល្វៃ និងមានឈ្មោះបុគ្គលពីររូបទៀតដែលគេបាននិយាយថាមានឋានៈស្មើនឹងល្វៃ ក្នុងនោះមានដូចជា តា ធួក និង តាស៊ូ ម៉េត[7]។ ទោះជាយ៉ាងណាក៏ដោយក៏ឈ្មោះដែលយើងទទួលបានទាំងនេះគឺទទួលបានពីសាក្សីមួយចំនួនដែលបានដឹងខ្លះៗពីរឿងនេះ និងកំពុងរស់រានមានជីវិតមកទាល់សព្វថ្ងៃ។

**ក.ដំណើរការសាងសង់៖**

ចំពោះការកសាងព្រលានយន្តហោះនេះមានការដ្ឋានប្រមាណជា ១៤កន្លែង នៅព័ទ្ធជុំវិញដែលបម្រើការឱ្យការដ្ឋានព្រលាន ក្នុងនោះមានដូចជា ការដ្ឋានយកថ្ម ការដ្ឋានផ្លូវថ្នល់ ការដ្ឋានអារឈើជាដើម[8]។ ហើយកម្មករដែលធ្វើការនៅទីនោះមិនមានសិទ្ធិចេញចូលតាមអំពើចិត្តនោះឡើយ។ តាមរយៈឯកសារ និងព័ត៌មាន បានលើកឡើងថាកម្មករទាំងអស់នោះ ភាគច្រើនជាកងទ័ពមកពីភូមិភាគបូព៌ា ដែលត្រូវបានអង្គការចោទប្រកាន់ថាមានសមាសភាពមិនល្អ ហើយមួយចំនួនទៀតបញ្ជូនមកពីភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ។ កងទ័ពទាំងនោះ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ហើយខ្លះទៀតត្រូវបញ្ជូនអោយមកលុតដំ ឬ អប់រំកែប្រែនៅការដ្ឋានសាងសង់ព្រលានយន្តហោះនេះ។[9]

ក្នុងដំណើរការនៃការសាងសង់ដំបូងៗ បានចាប់ផ្តើមឡើងនៅដើមឆ្នាំ១៩៧៦។ ការងារដំបូងដែលកម្មករត្រូវធ្វើនោះគឺ ទៅបោសសម្អាតនៅទីតាំងព្រលាននោះដោយដៃមួយទៅពីរសប្តាហ៍។ ប្រភេទការងារដែលពួកកម្មករទាំងនោះត្រូវធ្វើគឺ រៀបចំកន្លែងមួយ

---

[7] បញ្ជាការដ្ឋានកងទព័ជើងអាកាស(មូលដ្ឋានទព័អាកាសកំពង់ឆ្នាំង). ប្រវត្តិសង្ខេបនៃព្រលានយន្តហោះកំពង់ឆ្នាំង

[8] បទសម្ភាសន៍, សំ យ៉ុម ប្រជាជនមូលដ្ឋានៅភូមិក្រាំងលាវនាសម័យខ្មែរក្រហម, រសៀលថ្ងៃទី ១៦ សីហា ២០១៧

[9] អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,*សុំណុំរឿង០០២,* ១៩កញ្ញា២០០៧-ECCC-OCIJ, លេខ/No: D427,ទំព័រ១៣១

ចំនួនសម្រាប់យកថ្ម និងគាស់កកាយដើមឈើ ឬ ឫសឈើទាំងឡាយណាដែលនៅពាំង ការដ្ឋាន។ ក្រោយមកទៀតគេចាប់ផ្ដើមដឹកគ្រឿងយន្តមួយចំនួនមកដាក់នៅការដ្ឋាននេះ ហើយគ្រឿងយន្តទាំងនោះ ត្រូវបានដឹកបញ្ជូនមកពីកំពង់ផែអន្តរជាតិកំពង់សោមដែលមាន នាវារបស់ចិន និងកូរ៉េខាងជើងមកសំចត នេះបើតាមសាក្សីម្នាក់បាននិយាយរៀបរាប់ [10]។

ការដ្ឋាននេះត្រូវបានគេពន្លឿនយ៉ាងឆាប់រហ័សនៅក្នុងឆ្នាំ ១៩៧៧។ ចំណែកឯ ចំនួនកម្មករមានការកើនឡើងជាលំដាប់។ ក្នុងដំណើរការសាងសង់ កងទ័ពភូមិភាគបូព៌ា មួយចំនួនធំត្រូវបានគេឱ្យធ្វើការតែការដ្ឋានរូងភ្នំ ហើយយុទ្ធជនមកពីភូមិភាគពាយ័ព្យ និងយុទ្ធជនភូមិភាគបូព៌ាមួយចំនួនទៀត គេបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានយកថ្ម និងពិដាន ហើយនៅក្នុងនោះក៏មានការដ្ឋានបំផ្ទុះថ្មផងដែល។ គេអាចដឹងថាការដ្ឋាននោះ គឺស្ថិតនៅ លើភ្នំតាបាំងក្នុងពេលបច្ចុប្បន្ន។ ចំណែកឯកម្មករដែលជាស្ត្រី ភាគច្រើនត្រូវបានគេឱ្យធ្វើការ នៅទីតាំងផ្លូវរត់យន្តហោះ[11]។

ទោះបីព្រលានយន្តហោះកំពង់ឆ្នាំងសាងសង់ក្នុងរយៈពេលខ្លីក៏ដោយ ក៏ប៉ុន្តែគេ សង្កេតឃើញថាការសាងសង់ព្រលានយន្តហោះហាក់មានសន្ទុះលឿន ព្រោះចំណាយពេល ប្រហែលជា៣ឆ្នាំប៉ុណ្ណោះ ការដ្ឋាននេះបានសម្រេចសមិទ្ធផលស្ទើរតែរួចរាល់។ រហូតដល់ ដើមឆ្នាំ១៩៧៩ ការដ្ឋាននេះត្រូវបានបញ្ឈប់ការសាងសង់ ដោយសារតែមានការវាយលុក ពីកងទ័ពរណសិរ្សសង្គ្រោះជាតិ និងកងទ័ពវៀតណាម[12]។

**ខ. បច្ចេកទេស ៖** នៅក្នុងរយៈពេលសាងសងនៅក្នុងទីតាំងព្រលានយន្តហោះ មានការផ្ដល់ជំនួយជាច្រើនពីសំណាក់ប្រទេសដែលជាដៃគូ ដូចជាប្រទេសចិន និងកូរ៉េខាង ជើងជាដើម។ នៅចុងឆ្នាំ ១៩៧៦ មានជំនួយការចិនចំនួន ៥០ បានមកដល់ប្រទេស កម្ពុជាដើម្បីធ្វើការបង្រៀនក្បាច់គុណ និងបច្ចេកទេសក្នុងការកសាងព្រលានយន្តហោះ។ អ្នកដែលទទួលបានការបង្ហាត់បង្រៀនរបស់ជនជាតិចិនទាំងនោះ សុទ្ធតែជាអ្នកដែលមាន

---

[10] មជ្ឈមណ្ឌលសោតទស្សន៍បូផាណា, តាមវីដេអូ

[11] បទសម្ភាសន៍, សំ យ៉ុម ប្រជាជនមូលដ្ឋាននៅភូមិក្រាំងលាវនាសម័យខ្មែរក្រហម, រសៀលថ្ងៃទី ១៦ សីហា ២០១៧

[12] អ.វ.ត.ក. ២០១០, *សាលដីកាដំណោះស្រាយ*, ទំ.

ឋានៈចាប់ពីប្រធានកងអនុសេនាតូចឡើងទៅ ហើយអ្នកទាំងនោះត្រូវបង្ហាត់បង្រៀនកូនទាហានតូចៗផ្សេងទៀតក្រោយពេលដែលពួកគាត់បានបញ្ចប់មេរៀន។

នៅដើមឆ្នាំ ១៩៧៦ ក្រោយពីបានរៀបចំទីតាំងរួចរាល់មក គេបញ្ជារឱ្យពួកកម្មករចាប់ផ្តើមកសាងផ្លូវរត់យន្តហោះដែលមានរាងជាស្នូកអណ្តើក ដោយធ្វើការវាយបំបែកយកថ្មដោយប្រើប្រាស់ញញួរ។ គេដឹកថ្មទៅក្រាលលើគ្រឹះផ្លូវយន្តហោះយ៉ាងស្មើ រួចមកគេបានយកឥដ្ឋទៅតម្រៀបបញ្ឈរពីលើថ្មគ្រឹះទាំងនោះ និងចាប់ផ្តើមបាចស៊ីម៉ង់ត៍ពីលើឥដ្ឋទាំងនោះបន្តិចម្តងៗ ដោយការពារមិនអោយឥដ្ឋទាំងនោះដួលឡើយ។ ក្រោយមកទើបគេយកស៊ីម៉ង់ត៍ ដែលគេចាក់ពុម្ពរួចទៅដាក់ពីលើឥដ្ឋទាំងនោះម្តងមួយៗ។ មូលហេតុដែលគេចាក់ពុម្ពនេះ ព្រោះងាយស្រួលក្នុងការផ្លាស់ប្តូរផ្ទាំងស៊ីម៉ង់ត៍ នៅពេលដែលមានឧបទ្ទវហេតុ ឬបញ្ហាណាមួយកើតឡើង។

ម្យ៉ាងទៀតនៅព្រលានយន្តហោះនោះមានចំណតធំមួយ ព្រមទាំងមានទីតាំងជម្រាលនៅពីក្រោយចំណត និងនៅខាងឆ្វេងនៃចំណត។ ទីជម្រាលនេះធ្វើពីបេតុងសម្រាប់ការពារកុំឱ្យឆេះស្មៅ ឬព្រៃ និងខ្ទប់សម្លេងកុំឱ្យឮខ្លាំងចេញមកខាងក្រៅ នៅពេលដែលគេធ្វើការពិនិត្យយន្តហោះចម្បាំងខ្នាតតូចម្តងៗ។ មិនត្រឹមតែប៉ុណ្ណោះនៅលើចំណតនោះគេថែមទាំងមានធ្វើដែកស្នឹងជាច្រើនសម្រាប់ចាប់កង់យន្តហោះ នៅពេលយន្តហោះចុះចត និងពេលសាកយន្តហោះ។ ចំណែកឯផ្លូវយន្តហោះវិញគេធ្វើកម្រាស់២.៥តឹក ហើយនៅសងខាងនៃក្បាលផ្លូវគេធ្វើកម្រាស់ក្រាស់ជាងផ្នែកកណ្តាល។ សម្រាប់ទប់ទល់នៅពេលដែលយន្តហោះចុះចត។ ផ្នែកសងខាង និងកណ្តាលនៃផ្លូវយន្តហោះមានប្រព័ន្ធលូ សម្រាប់បង្ហូរទឹកចេញនៅពេលដែលមានមេឃភ្លៀងធ្លាក់ ព្រមទាំងគម្របលូយ៉ាងក្រាស់ផងដែរ។[13]

នៅភ្នំតាបាំងមានបាសាំងចំនួន៦ ដែលត្រូវបានបង្កប់នៅចង្កេះភ្នំ ព្រមទាំងបង្កប់បំពង់បង្ហូរសាំងពីភ្នំ ទៅទីតាំងចំណត។ បាសាំងទាំង៦នោះធ្វើឡើងពីបេតុង និងមានពោងដែលធ្វើពីកៅស៊ូនៅពីខាងក្នុង។ ពោងកៅស៊ូនេះធ្វើឡើងសម្រាប់ការពារកុំឱ្យមានការជ្រាប

---

[13] បញ្ជាការដ្ឋានកងទ័ពជើងអាកាស(មូលដ្ឋានទព័អាកាសកំពង់ឆ្នាំង). ប្រវត្តិសង្ខេបនៃព្រលានយន្តហោះកំពង់ឆ្នាំង

សាំងចេញ។ ចំណែកឯផ្នែកបេតុង ការពារផ្នែកខាងក្រៅនៃពោង ដើម្បីកុំឱ្យផ្ទុះនៅពេលគេបញ្ចូលសាំង។

ក្នុងតំបន់នេះមានភ្នំសំខាន់ចំនួនបីទៀតទី១ គឺភ្នំទេសនាមានរាងជាក្រចកសេះដែលជាទីតាំងសំខាន់មួយសម្រាប់លាក់យន្ត ការពារនៅពេលដែលព្រលានមានការវាយប្រហារពីខាងក្រៅ។ ភ្នំតារាជ មានការជីករូងភ្នំមួយសម្រាប់ធ្វើជាទីបញ្ជាការទៅលើការដ្ឋានយន្តហោះទាំងមូល។ ចំណែកភ្នំក្រាំងជីមាស មានដាក់រ៉ាដាមួយសម្រាប់ចាប់យន្តហោះនៅពេលមានយន្តហោះចូលមកក្នុងតំបន់។

គួរបញ្ជាក់ផងដែរថា នៅក្នុងដំណើរការនៃការសាងសង់មានជំនាញការចិនជាច្រើនរូបដែលបានមកត្រួតពិនិត្យការដ្ឋាននេះ។ បើតាមសាក្សីម្នាក់បាននិយាយថា គេបានបែងចែកកម្មករជាពីរក្រុមដែលត្រូវបានបង្ហាត់បង្ហាញពីក្រុមជនជាតិចិន ក្រុមទីមួយគេបង្ហាត់ពីរបៀបតំឡើងលួស និងមួយក្រុមទៀតបង្រៀនពីការបំបែកថ្ម។ វាអាចបង្ហាញថា ចំពោះដំណើរការសាងសង់នេះ គឺទទួលបានបច្ចេកទេស ឬមេរៀនមួយចំនួនពីជនជាតិចិន។[14]

### ២.៣.២. ស្ថានភាពរបស់កម្មករ

ព្រលានយន្តហោះនៅក្នុងខេត្តកំពង់ឆ្នាំង គឺជាព្រលានយន្តហោះសម្រាប់ប្រើប្រាស់ជាមូលដ្ឋានកងទ័ពអាកាស។ យុទ្ធជនដែលគេបញ្ជូនទៅធ្វើការសាងសង់នៅទីនោះ គឺសុទ្ធសឹងតែជាកងទ័ពបដិវត្តន៍របស់បក្សកុម្មុយនិស្តកម្ពុជាទាំងអស់។ កម្មករទាំងនោះ គឺសុទ្ធតែត្រូវបានគេចោទប្រកាន់ថាជាកងទ័ពមានសមាសភាពមិនល្អ ឬអាចត្រូវបានគេចោទថាមិនស្មោះត្រង់នឹងអង្គការ។ មូលហេតុដែលគេបញ្ជូនយុទ្ធជនទាំងនោះមកធ្វើការនៅទីតាំងនេះ គឺដើម្បីធ្វើការលុតដំ និងកសាងខ្លួនឡើងវិញ។ ជាពិសេសកងទ័ពដែលត្រូវបានបញ្ជូនមកពីភូមិភាគបូព៌ាដែលត្រូវបានគេចោទប្រកាន់ថាជាកងទ័ពមានសមាសភាពមិនល្អ ហើយត្រូវបានគេចាប់បញ្ជូនឱ្យមកអប់រំកែប្រែនៅការដ្ឋាននេះជាច្រើននាក់ និងត្រូវធ្វើការជាទម្ងន់។ ចំនួនកម្មករមានការកើនឡើងជាលំដាប់ ដោយរាប់ចាប់ពីការសាងសង់ដំបូងមានចំនួន

---

[14] ហ៊ុល រស្មី, ២៣មិថុនា២០១៥, *អតីតទាហានខ្មែរក្រហមផ្តល់សក្ខីកម្មអពីទារុណកម្មនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង*

តិចតួច នឹងបានកកើនឡើងរហូតដល់ជាងមួយម៉ឺននាក់បើរាប់ត្រឹមឆ្នាំ ១៩៧៧ ហើយបន្តកើនឡើងច្រើនជាងទៅទៀត។[15]

កម្មករទាំងនោះត្រូវធ្វើការទៅតាមកម្រិតនៃទោសរបស់ពួកគេ។ កម្មករមួយចំនួនត្រូវធ្វើការពីម៉ោង ៧ព្រឹក រហូតដល់ ម៉ោង១១ព្រឹក និងបន្តពីម៉ោង ១ រហូតដល់ ម៉ោង ៥ល្ងាច ហើយមានកម្មករមួយចំនួនទៀតត្រូវធ្វើការនៅវេនយប់ មានកម្មករខ្លះទៀតត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ដោយសារតែកម្មករទាំងនោះមានកម្រិតទោសធ្ងន់ធ្ងរ។ សាក្សីមួយចំនួនបានអះអាងថាពួកគាត់បាន ឃើញកម្មករខ្លះត្រូវធ្វើការទាំងយប់ទាំងថ្ងៃ និងមិនមានសុវត្ថិភាពឡើយ។ ចំណែកឯកម្មករជាស្ត្រីវិញ ក៏ត្រូវធ្វើការតាមការអនុម័តរបស់មេដឹកនាំនៅកន្លែងនោះផ្ទាល់ដែរ។ ប៉ុន្តែរហូតដល់ចុងឆ្នាំ ១៩៧៦ កម្មករស្ត្រីភាគច្រើនបានបាត់ខ្លួន ជាពិសេសកម្មករស្ត្រីដែលមកពីភូមិភាគបូព៌ា។

ការហូបចុករបស់ពួកកម្មករនៅការដ្ឋានមិនទទួលបានរបបអាហារគ្រប់គ្រាន់ និងស្នាក់នៅសមរម្យនោះទេ។ ផ្ទុយទៅវិញកម្មាភិបាលដែលកាន់កាប់នៅការដ្ឋាន និងអ្នកជំនាញការចិន បែរជាទទួលបានរបបអាហារគ្រប់គ្រាន់ និងស្នាក់នៅយ៉ាងសុខស្រួលទៅវិញ។ អ្នកជំនាញការចិន អាចស្នាក់នៅអាគារប្រាំជាន់នៅពេលថ្ងៃ ហើយពេលយប់ពួកគេបានទៅស្នាក់នៅទីរួមខេត្តកំពង់ឆ្នាំង។ ជារៀងរាល់ថ្ងៃគេតែងតែឃើញមនុស្ស ២០ទៅ៣០ នាក់ដើរស្វែងរកបន្លែសម្រាប់យកមកធ្វើម្ហូបដូចជា ដើរបេះត្រកួន ព្រលិត ឬស្ទូចកង្កែបដើម្បីផ្គត់ផ្គង់របបអាហារដល់ពួកកម្មករ ប៉ុន្តែអ្នកទាំងនោះមិនដែលបានទៅជិតការដ្ឋានឡើយ គឺគេគ្រាន់តែបំពេញការងាររបស់គេ និងគ្មានសិទ្ធចូលទៅក្នុងទីតាំងការដ្ឋានឡើយ រហូតដល់ម៉ោងបាយ និងមានអ្នកផ្សេងទៀតមកយកអាហារទៅការដ្ឋានដើម្បីចែកជូនដល់ពួកកម្មករ[16]។

---

[15] អង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ,០០២សុំណុំរឿង,១៩កញ្ញា២០០៧-ECCC-OCIJ, លេខ/No: D427១២៨ទំព័រ,

[16] [16] បទសម្ភាសន៍, សំ យ៉ុម ប្រជាជនមូលដ្ឋានៅភូមីក្រាំងលាវនាសម័យខ្មែរក្រហម, រសៀលថ្ងៃទី ១៦ សីហា ២០១៧

កម្មករជាច្រើនបានស្លាប់ដោយសារតែ ទទួលរងគ្រោះថ្នាក់ក្នុងអំឡុងពេលសាង-សង់ ការធ្វើការងារលើសកម្លាំង ការទទួលបានរបបអាហារមិនគ្រប់គ្រាន់ ការធ្វើអត្តឃាត និងមួយចំនួនទៀតបានបាត់ខ្លួនដោយគ្មានមូលហេតុច្បាស់លាស់។ រាល់ពេលគេប្រើប្រាស់ធ្នូនសម្រាប់បំផ្ទុះថ្ម តែងតែមានកម្មករស្លាប់ និងរងរបួសពីបំណែកថ្មជានិច្ច។ ក្នុងអំឡុងពេលមានកម្មកររងរបួស ប្រសិនបើកម្មករផ្សេងទៀតទៅឈរមើលអ្នករបួស នោះពួកគេត្រូវបាត់ខ្លួន។ ចំណែកឯកម្មកររបួសទាំងនោះវិញខ្លះត្រូវដេកចាំរហូតដល់ឡានពេទ្យមកដល់ទើបលើកដាក់ឡានយកទៅ ប៉ុន្តែមិនដឹងថាយកទៅណា ហើយក៏មិនដឹងថាត្រូវត្រឡប់មកវិញពេលណាដែរ។ ជនរងគ្រោះទាំងនោះត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង ប៉ុន្តែមិនដែលបានឃើញនរណាម្នាក់ត្រឡប់មកវិញទេ ហើយអ្នកខ្លះទៀតត្រូវស្លាប់មុនពេលឡានពេទ្យមកដល់ទៅទៀត។[17]

នៅការដ្ឋានសាងសង់នេះក៏ឃើញមានការធ្វើប្រជុំទិតៀន និងស្វ័យទិតៀន ហើយវាក៏ប្រហែលជាមូលហេតុមួយ ដែលបណ្តាលឱ្យមានការបាត់ខ្លួនពួកកម្មករច្រើនលើសលប់ដែរ។ ក្រោយការប្រជុំធ្វើទិតៀន និងស្វ័យទៀន គេតែងតែឃើញឡានដឹកកម្មករមួយក្រុមចេញទៅក្រៅ តែមិនដឹងថាមានគោលដៅទៅណានោះទេ។ ចំណែកឯការធ្វើទិតៀន និងស្វ័យទិតៀននេះគេតែងតែនិយាយថា ឈឺ ខ្ជិលច្រអូស ឬបានប្រព្រឹត្តកំហុសតិចតួចក្នុងពេលធ្វើការ ឬរងការចោទប្រកាន់ថាមានទំនាក់ទំនងជាមួយពួកកងទ័ពវៀត-ណាម។

នៅក្នុងឆ្នាំ ១៩៧៨ មានការដ្ឋានជីករូងភ្នំដែលមានមេការជាជនជាតិចិនម្នាក់ឈ្មោះថា រ៉ុង ដែលជាអ្នកទទួលខុសត្រូវលើការខួងរូងភ្នំសម្ងាត់នោះ។ បើតាមសាក្សីម្នាក់បាននិយាយថា ការជីករូងភ្នំនេះគឺគេបានបែងចែកជាកង ដោយមួយកងមានគ្នាចំនួន១២ ទៅ ១៥នាក់ ហើយនៅពេលដែលធ្វើការ គេបញ្ជូនកងទាំងនោះម្តងមួយកងៗឱ្យទៅធ្វើការក្នុងរូងភ្នំនោះ។[18] ក៏ប៉ុន្តែកម្មករដែលបានចូលទៅធ្វើការនៅទីនោះតែងតែបាត់ខ្លួនជាសម្ងាត់

---

[17] ហ៊ុល រស្មី, ២៣មិថុនា២០១៥, *អតីតទាហានខ្មែរក្រហមផ្តល់សក្ខីកម្មអពីទារុណកម្មនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង*

[18] មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០២, *ទំនាក់ទនងចិន និងកម្ពុជាប្រជាធិបតេយ្យ.* ទស្សនាវដ្តីស្វែងរកការពិតលេខ២៥. ទំព័រ២៩ដល់៣០

ដោយគេជឿថាកម្មករមួយចំនួនបានដាច់ខ្យល់ស្លាប់ដោយសារគ្មានអុកស៊ីសែនគ្រប់គ្រាន់ និងមួយចំនួនទៀតត្រូវបានគេយកទៅសម្លាប់ចោលជាសម្ងាត់តែម្តង ព្រោះដើម្បីកុំអោយបែកធ្លាយពីការសាងសង់នេះ។ គេឃើញមានឡានដឹកកម្មករចេញ ហើយបានឈប់មិនឆ្ងាយប៉ុន្មានពីការដ្ឋាននោះ។ ក្រោយពីឡានបានឈប់មួយស្របក់គេឮសម្លេងស្រែកយំរបស់មនុស្ស ហើយកន្លងផុតប្រហែលជាមួយសប្តាហ៍គេធុំក្លិនស្អុយដែលបណ្តាលមកពីការរលួយនៃសាកសព។ ក៏ប៉ុន្តែមិនមាននរណាម្នាក់បានឃើញពីការសម្លាប់ដោយផ្ទាល់នៅទីតាំងព្រលានយន្តហោះនោះឡើយ។ យ៉ាងណាមិញចំនួននៃការបាត់ខ្លួនរបស់ពួកកម្មករទាំងនោះក៏ត្រូវបានគេរកឃើញថាមានកម្មករខ្លះត្រូវបានគេចាប់បញ្ជូនមកទីក្រុងភ្នំពេញវិញ ដែលទំនងដូចជាត្រូវបញ្ជូនចូលទៅក្នុងមន្ទីសន្តិសុខ ស-២១ ដើម្បីធ្វើបន្សុទ្ធកម្ម មុននិងធ្វើការសម្លាប់។

ចំណែកឯទីតាំងកប់សាកសពរបស់ពួកកម្មករទាំងនោះ ខ្លះស្ថិតក្នុងព្រៃមួយនៅជិតវត្តស្ទឹងដែលនៅមិនឆ្ងាយប៉ុន្មានពីព្រលានយន្តហោះ និងមានអ្នកខ្លះទៀតនិយាយថានៅភាគខាងលិចដែលមិនឆ្ងាយប៉ុន្មានពីការដ្ឋានព្រលាននេះ។ រហូតមកដល់ពេលបច្ចុប្បន្នគេបានដឹងថា យ៉ាងហោចណាស់ក៏មានចំនួនមនុស្សលើលពី១ម៉ឺននាក់ ដែលបានស្លាប់ដោយសារតែឧបទ្ទវហេតុ ការសម្លាប់ និងការបាត់ខ្លួន។[19] ទោះជាព្រលានយន្តហោះនេះបានចំណាយពេលខ្លីក្នុងការសាងសង់ក៏ដោយ ក៏ប៉ុន្តែគេសង្កេតឃើញថាការសាងសង់ព្រលានយន្តហោះហាក់មានសន្ទុះលឿន ព្រោះចំណាយពេលប្រហែលជា៣ឆ្នាំប៉ុណ្ណោះការដ្ឋាននេះបានសម្រេចសមិទ្ធិផលស្ទើរតែរួចរាល់។ រហូតដល់ដើមឆ្នាំ១៩៧៩ ការដ្ឋាននេះត្រូវបានបញ្ឈប់ការសាងសង់ ដោយសារតែមានការវាយលុកពីកងទ័ពរណសិរ្សសង្គ្រោះជាតិ និងកងទ័ពវៀតណាម។ កម្មករមួយចំនួនធំបានធ្វើដំណើរទៅកាន់ស្ថានីយរថភ្លើងរមាសដែលមានចម្ងាយប្រមាណ ២០គីឡូម៉ែត្រពីការដ្ឋាន និងមួយចំនួនទៀតគេបង្ខំអោយកាន់កាំភ្លើងតស៊ូជាមួយពួកកងទ័ពវៀតណាម ចំណែកឯកម្មករមកពីភូមិភាគបូព៌ាត្រូវបាន

គេយកទៅសម្លាប់ចោលនៅវត្តមង្គលខ័ណ្ឌ ភូមិទួលខ្ពស់។ រីឯជំនាញការចិនទាំងអស់ត្រូវបានដឹកចេញតាមឡានគេចផុតមុនពេលពួកវៀតណាមមកដល់។

**២.៣.៣. រចនាសម្ពន្ធ័គ្រប់គ្រងនៅក្នុងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង**

ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ជាព្រលានមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការដ្ឋាន និងអគ្គសេនាធិការនៃក្រសួងការពារជាតិ។ សុន សេន ជាអគ្គសេនាធិការនៃអគ្គសេនាធិការដ្ឋានក្រសួងការពារជាតិ និងជាកម្មាភិបាលជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[20]។ កងពល៥០២ទ័ពអាកាសកម្ពុជា ជាកងពលដែលបានបង្កើតឡើងក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានទទួលបន្ទុកត្រួតពិនិត្យមើលការដ្ឋាននោះដោយផ្ទាល់។ ប៉ុន្តែកងពលនេះ ត្រូវតែធ្វើរបាយការណ៍ ដោយផ្ទាល់ទៅអគ្គសេនាធិការដ្ឋាន។ ជាងនេះទៅទៀត ប្រធានកងពល៥០២ មិនមានឯកសារឬសាក្សីណាមួយបញ្ជាក់ថាគាត់ជានរណា ហើយគាត់បានធ្វើអ្វីខ្លះឱ្យច្បាស់លាស់នោះទេ។

ក្រៅពីអ្នកគ្រប់គ្រងនៅទីនោះផ្ទាល់ ក៏មានកម្មាភិបាលជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យមួយចំនួនដូចជា នួន ជា អៀង សារី និងកែ ពក មកពិនិត្យមើលការដ្ឋាន និងបានជួបជាមួយថ្នាក់ដឹកនាំនៅទីនោះ។ រីឯ ខៀវ សំផន ក៏បានមកពិនិត្យមើលការដ្ឋាននោះនៅក្នុងឆ្នាំ១៩៧៧ដែរ[21]។ ចំពោះការគ្រប់គ្រងនៅទីនោះ« *គេធ្វើការបែងចែក ជាផ្នែកៗ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការតាមដានរកខ្មាំងស៊ីរូងផ្ទៃក្នុង*» វាជាវិធីដែលខ្មែរក្រហមប្រើក្នុងការរកខ្មាំងបង្កប់[22]។ ចាប់ពីឆ្នាំ១៩៧៦ ខ្មែរក្រហមបានធ្វើវិសុទ្ធកម្ម និងរិតបន្តឹងបទបញ្ជាបក្សឱ្យបានប្រសើរជាងមុន។ ចំណែកឯអ្នកគ្រប់គ្រង ត្រូវបានស្គាល់ថាឈ្មោះ ល្វៃ ជាអ្នកមើលការខុសត្រូវនៅទីនោះ ហើយគាត់បានកាន់កងពលពាវរៈ[23]។ ល្វៃ ត្រូវបានគេចាប់បញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងឆ្នាំ១៩៧៨[24] ដោយមិនបានដឹង

---

[20]អ.វ.ត.ក,សំណុំរឿង០០២,១៩កញ្ញា១៧-ECCC-OCIJ,លេខ/No:D247.ទំ.១២៨

[21]អ.វ.ត.ក,សំណុំរឿង០០២,១៩កញ្ញា១៧-ECCC-OCIJ,លេខ/No:D247.ទំ....

[22] ហ៊ីង ស៊ុនតារា,*មេបញ្ជាការរងនៃកងទ័ពអាកាសកម្ពុជា,*អាយុ ,១៦សីហា១៧

[23] លឿង គឹមធុង,*អតីតប្រជាជនធ្លាប់ចូលការដ្ឋាន*,អាយុ,កិច្ចសម្ភាសន៍ផ្ទាល់,១៧សីហា១៧

[24] សំ យ៉ុម,*ប្រជាជនមូលដ្ឋាន,*អាយុ៦០,កិច្ចសម្ភាសន៍ផ្ទាល់,១៦កញ្ញា១៧

ច្បាស់ពីមូលហេតុនៃការបញ្ជូនទៅនោះទេ។ ក្រៅពីនេះ ប្រធានដែលទទួលបន្ទុកមើលការខុសត្រូវក្រៅពី ល្វៃ មានអ្នកផ្សេងទៀតគឺ តាជួក និងតាម៉េត(ស៊ូ ម៉េត)[25]។ ចំពោះរចនាសម្ព័ន្ធនៃការគ្រប់គ្រង នៅក្នុងការដ្ឋានព្រលានយន្តហោះនេះ មិនមាននរណាម្នាក់អាចបញ្ជាក់ឲ្យបានច្បាស់លាស់នោះទេ។

### ២.៣.៤. មន្ទីរសន្តិសុខ និងការសម្លាប់

#### ក. ការសម្លាប់

កម្ពុជាប្រជាធិបតេយ្យបានអនុវត្តន៍គោលនយោបាយ ក្នុងការរកខ្មាំងស៊ីរូងផ្ទៃក្នុងតាមរយៈការធ្វើវិសុទ្ធកម្ម ដែលបានប្រល័យជីវិតដ៏ស្លូតត្រង់របស់ប្រជាជនខ្មែរ អស់រាប់លាននាក់។ ជាក់ស្តែងការសាងសង់ព្រលានយន្តហោះយោធាមួយនៅក្នុងខេត្តកំពង់ឆ្នាំងមានយុទ្ធជនជាច្រើនដែលត្រូវបានខ្មែរក្រហមគិតថាមានសមាសភាពមិនល្អ និងត្រូវបានបញ្ជូនទៅធ្វើការនៅទីនោះ។[26] ការងារនៅទីនោះភាគច្រើនប្រឈមមុខជាមួយគ្រោះថ្នាក់ស្ទើរគ្រប់ពេលវេលា ក្នុងនោះមានដូចជាការងារនៅក្នុងព្រលានយន្តហោះ និងដំណើរការជីករូងភ្នំជាដើម។ ក្នុងដំណើរការជីករូងភ្នំនេះ គេត្រូវការយុទ្ធជនចន្លោះពី ១២ទៅ ១៥នាក់ម្តង ដើម្បីបំផ្ទុះថ្មភ្នំ ឬជីកវាឲ្យក្លាយជារូងភ្នំលាក់យន្តហោះបាន។ គេតែងតែផ្លាស់ប្តូរវេន ឱ្យក្រុមយុទ្ធជនផ្សេងទៀត ធ្វើបែបនេះដូចក្រុមមុនៗដែរ។ តាមរយៈការធ្វើបែបនេះជារឿយៗធ្វើឲ្យកម្មករត្រូវបាត់បង់ជីវិតជាច្រើន ដោយសារថ្មភ្នំធ្លាក់សង្កត់ពីលើ និងអំបែងធ្នូនដែលគេប្រើសម្រាប់បំផ្ទុះថ្មទាំងនោះខ្ទាតប៉ះ។ គ្រោះថ្នាក់បានបណ្តាលឱ្យកម្មករត្រូវដាច់ក្បាល ដាច់ដៃ ដាច់ជើងយ៉ាងអាណោចអធម្មណាស់។[27]ខ្មែរក្រហមធ្វើបែបនេះគឺដោយសារតែចង់ទាញយកផលប្រយោជន៍ពីយុទ្ធជនទាំងនោះរួចហើយទើបសម្លាប់ជាក្រោយ។ យុទ្ធជនដែលចូលទៅជីករូងភ្នំនោះ ភាគច្រើនមិនដែលឃើញត្រលប់ទៅការដ្ឋានវិញទេ។ យុទ្ធជនខ្លះទៀតដែលត្រូវកម្ទេចធ្នូនខ្ទាតប៉ះ ហើយមានរបួសធ្ងន់ស្ទើរតែបាត់បង់

[25] ឆេង វេង, *ទស្សនាវដ្តីស្វែងរកការពិត*, លេខ៥៥ , (កក្កដា, ២០០៤).ទំ១៤

[26] ហ៊ីង ស៊ុនតារា,*មេបញ្ជាការរងនៃកងទ័ពអាកាសកម្ពុជា.*១៦ ០៨ ២០១៧

[27] អែម សុខឃឹម,ទស្សនាវដ្តីស្វែងរកការពិត,លេខ៥៥កញ្ញា២០០៤.ទំ២៦-២៧

ជីវិតត្រូវគេបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។ កម្មករខ្លះទៀតត្រូវ បានបាត់បង់ជីវិតនៅពេលបញ្ជូនមកមន្ទីរពេទ្យ។

**ខ. មន្ទីរសន្តិសុខ**

ក្រៅពីយុទ្ធជនទាំងនោះ កម្មាភិបាល ដែលគេចោទប្រកាន់មិនស្មោះត្រង់ជាមួយនឹងបដិវត្តន៍ត្រូវបានគេបញ្ជូនទៅមន្ទីសន្តិសុខ ស-២១(គុកទួលស្លែង) និងមន្ទីរ ស-២៤ (គុកព្រៃស) ដែលជាគុកកំពូលនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងឆ្នាំ ១៩៧៨ ល្វៃ ត្រូវបានគេបញ្ជូនទៅទីនោះ ដោយសារតែគេចាត់ទុកគាត់ថាជាមនុស្សដែលមានមនោសញ្ចេតនាច្រើន ហើយមិនអាចសម្រេចភារកិច្ចធំបាន[28]។ ស្របពេលជាមួយនឹងល្វៃ ក៏មានយុទ្ធជនមួយចំនួនដែលគេបញ្ជូនទៅភ្នំពេញដែរ ហើយវាសនារបស់ពួកគេគ្មានអ្វីក្រៅពី សេចក្តីស្លាប់នោះទេ។ ប៉ុន្តែយុទ្ធជនមួយចំនួនទៀត មិនត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខទេ ប៉ុន្តែគេបញ្ជូនពួកគាត់ទៅប៉ែកខាងលិចព្រលានយន្តហោះវិញ។

ចំពោះទីតាំងសម្លាប់ទាំងនោះគេបានធ្វើនៅក្បែរស្ថានីយ៍រថភ្លើងរមាស ដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីព្រលានយន្តហោះ និងទីតាំងមួយទៀតស្ថិតនៅក្នុងព្រៃក្បែរវត្តស្ទឹង ដែលជាកន្លែងកប់សាកសពយុទ្ធជនទាំងនោះ។[29] ចំពោះការសម្លាប់ គេបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗដូចជា ពេលខ្លះគេប្រើដែកគ្លៀរទេះ និងពូថៅ ហើយពេលខ្លះគេបាញ់រះទៅលើយុទ្ធជនដោយផ្ទាល់[30]។ ក្រោយមកនៅចុងឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ក្នុងតំបន់ យុទ្ធជនមួយចំនួនត្រូវបានខ្មែរក្រហមបំពាក់អាវុធ ធ្វើដំណើរឆ្ពោះទៅកាន់អមលាំង និងជិតភ្នំឱរ៉ាល(ខេត្តកំពង់ស្ពឺ) ប៉ុន្តែមិនមានឯកសារ ឬសាក្សីណាបានបញ្ជាក់ពីភារៈកិច្ចដែលពួកគេត្រូវធ្វើបន្តនោះទេ។ ការមិនទុកចិត្តគ្នា និងភាពភ័យខ្លាចបានធ្វើឱ្យខ្មែរក្រហមបំផ្លាញខ្លួនឯង តាមរយៈការធ្វើវិសុទ្ធកម្ម ដើម្បីបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង។ នៅទីបំផុតខ្មែរក្រហមបានទទួលបរាជ័យ តាមរយៈការធ្វើវិសុទ្ធកម្មដែលជាទង្វើផ្ទុយស្រឡះខុសពីការសន្យាថា ខ្លួននឹងធ្វើបដិវត្តន៍ដើម្បីជាតិនិងការពារទឹកដី។

---

[28] ហ៊ីង ស៊ុនតារា,*មេបញ្ជាការកងទ័ពអាកាសកម្ពុជា*, ១៦, ០៨, ២០១៧

[29] អែម សុខឃីម,ទស្សនាវដ្តីស្វែងរកការពិត,លេខ៥៥កញ្ញា២០០៤.ទំ២៥

[30] អែម សុខឃីម,ទស្សនាវដ្តីស្វែងរកការពិត,លេខ៥៥កញ្ញា២០០៤.ទំ២៦-២៧

## ២.៤. ការគ្រប់គ្រងក្រោយសម័យខ្មែរក្រហម

នៅដើមឆ្នាំ១៩៧៩ ទីតាំងសំខាន់ៗជាច្រើននៅក្នុងប្រទេសកម្ពុជាដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ត្រូវបានរំដោះដោយកងទ័ពរណសិរ្សរំដោះជាតិកម្ពុជា និងកងទ័ពវៀតណាម។ ក្នុងនោះខេត្តកំពង់ឆ្នាំងដែលជាទីតាំងដ៏សំខាន់របស់ខ្មែរក្រហមក្នុងការសាងសង់ព្រលានយន្តហោះ ក៏ត្រូវបានរំដោះផងដែរ។

នៅពេលដែលស្ថានការណ៍របស់ខ្មែរក្រហមកាន់តែស្ថិតនៅក្នុងភាពអាសន្ន គឺនៅពេលដែលកងកម្លាំងរណសិរ្សសង្គ្រោះជាតិ និងកងទ័ពវៀតណាមកំពុងចូលមករំដោះប្រទេសកម្ពុជា ពួកខ្មែរក្រហមបានជម្លៀសកម្មករនៅក្នុងការដ្ឋានទៅភាគខាងលិចព្រលានចំពោះអ្នកណាដែលគេសង្ស័យថាក្បត់គេបានសម្លាប់ចោល ចំណែកឯអ្នកដែលខ្មែរក្រហមទុកចិត្តថាស្មោះជាមួយនិងខ្លួន ត្រូវបានគេឲ្យទៅប្រឆាំងតទល់នឹងកងទ័ពវៀតណាម។ ទីតាំងព្រលានយន្តហោះ បានក្លាយទៅជាសមរភូមិយ៉ាងក្តៅគគុករវាងកងទ័ពខ្មែរក្រហមធ្វើការប្រយុទ្ធតតាំងជាមួយនឹងកងទ័ពវៀតណាម។ តែទោះបីជាយ៉ាងណាក៏ដោយក៏កងទ័ពរបស់ខ្មែរក្រហម មិនអាចធ្វើការទប់ទល់នឹងកងទ័ពវៀតណាមបានដែរ ជាលទ្ធផលកងទ័ពរបស់ពួកខ្មែរក្រហមត្រូវទទួលបរាជ័យ។ ក្រោយពីទទួលបានជោគជ័យ កងទ័ពរណសិរ្សសង្គ្រោះជាតិ និងកងទ័ពវៀតណាមជាអ្នកគ្រប់គ្រងនៅតំបន់ការដ្ឋានព្រលានយន្តហោះនេះព្រោះដើម្បីទប់ស្កាត់ការវិលមកវិញរបស់កងទ័ពខ្មែរក្រហម។ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងត្រូវបានគេទុកចោល និងពុំមានសកម្មភាពសាងសង់អ្វីទៀតឡើយ ប៉ុន្តែកន្លែងនេះបានក្លាយទៅជាទីតាំងឈរជើងរបស់យោធាខេត្ត និងក្លាយជាខ្សែក្រវ៉ាត់ការពារខេត្តកំពង់ឆ្នាំងដ៏សំខាន់មួយ។

### ២.៤.១. ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងសម័យ «អ៊ុនតាក់» ឆ្នាំ១៩៩២ រហូតដល់ពេលបច្ចុប្បន្ន

នៅឆ្នាំ១៩៩២ ពេលដែលកងទ័ពមួកខៀវ (អ៊ុនតាក់) ចូលមកប្រទេសកម្ពុជា ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងត្រូវបានកងកម្លាំងអ៊ុនតាក់ យកធ្វើជាទីតាំងឈរជើង។

នៅឆ្នាំ១៩៩៣ មុនពេលអ៊ុនតាក់ដកចេញទីតាំងព្រលានយន្តហោះនេះត្រូវបាន ក្រសួងការពារជាតិបានស្នើទៅនាយករដ្ឋមន្ត្រី សុំយកមកគ្រប់គ្រងដើម្បីបម្រើដល់កងទ័ពអាកាស។ ដោយមានការឯកភាពពីសម្តេចក្រុមព្រះ ជានាយករដ្ឋមន្ត្រីទី១ និងឯកឧត្តម ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ ទើបមានការផ្ទេរពីកងកម្លាំងអ៊ុន តាក់ មកកងទ័ពជើងអាកាសកម្ពុជា នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ ១៩៩៣។[31]

**ក. ជួរមេបញ្ជាការដែលមកគ្រប់គ្រងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង**

- ពីឆ្នាំ១៩៩៣ ដល់១៩៩៦
  - វរៈសេនីយ៍ឯក ខាំ សុវ៉ាំភី មេបញ្ជាការ
  - វរៈសេនីយ៍ទោ ទន់ ប៊ុនគា មេបញ្ជាការរង
  - វរៈសេនីយ៍ត្រី គុណ សម្បត្តិ៍ នាយកប្រតិបត្តិ
- ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ ១៩៩៩
  - វរៈសេនីយ៍ឯក សែស វង្សសត្ថា មេបញ្ជាការ
  - វរៈសេនីយ៍ទោ ហែន ឆាវ៉ាត់ មេបញ្ជាការរង
  - វរៈសេនីយ៍ទោ ទន់ ប៊ុនគា មេបញ្ជាការរង
  - វរៈសេនីយ៍ត្រី គុណ សម្បត្តិ៍ នាយកប្រតិបត្តិ
- ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៦
  - វរៈសេនីយ៍ឯក កែវ វណ្ណដេត មេបញ្ជាការ
  - វរៈសេនីយ៍ទោ កៅ យាន មេបញ្ជាការ
  - វរៈសេនីយ៍ទោ អ៊ុក ហន មេបញ្ជាការរង
  - វរៈសេនីយ៍ទោ ខឹមសារ៉េត មេបញ្ជាការ
- ពីឆ្នាំ ២០០៦ ដល់បច្ចុប្បន្ន

---

[31] ហ៊ីង ស៊ុនតារា មេបញ្ជាការរងនៃកងទ័ពអាកាសកម្ពុជា ១៦ ០៨ ២០១៧

- ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ វណ្ណដេត មេបញ្ជាការ
- ឯកឧត្តម ឧត្តមសេនីយ៍ត្រី កៅ ឃាន មេបញ្ជាការរង
- វរៈសេនីយ៍ សាន សុខុម មេបញ្ជាការ
- វរៈសេនីយ៍ ហ៊ីង ស៊ុនតារា មេបញ្ជាការ
- វរៈសេនីយ៍ មាស សុផន មេបញ្ជាការ
- វរៈសេនីយ៍ ធន់ ស៊ីវត្ថា មេបញ្ជាការ32

## ខ. សំណង់អាគារ និង សម្ភារៈនៅក្នុងការដ្ឋាន

សាក្សីជាច្រើនបានអះអាងថា មុនពេលខ្មែរក្រហមចាកចេញពីព្រលាន ខ្មែរក្រហមបានបំផ្លាញចោលនូវសម្ភារៈដែលមានតម្លៃជាច្រើន ប៉ុន្តែគេក៏ឃើញនូវការបន្សល់ទុកសម្ភារៈមួយចំនួនផងដែរដូចជា សម្ភារៈសំណង់ គ្រឿងចក្រ និងសម្ភារៈមានតម្លៃជាច្រើនទៀតដែលត្រូវបានគេទុកចោលនៅក្នុងការដ្ឋាននេះ។ ក្រោយពេលដែលកងទ័ពរណសិរ្សសង្គ្រោះជាតិ និងកងទ័ពវៀតណាមកាន់កាប់ទីនេះរួចមក សម្ភារៈទាំងប៉ុន្មានដែលមាននៅព្រលាននេះត្រូវបានគេដឹកជញ្ជូនទៅស្ទើរគ្មានសល់។ ក្រោយមកប្រជាជនដែលបន្តរស់នៅជុំវិញបរិវេណព្រលាននេះ បានទៅយកសម្ភារៈមានតម្លៃតិចតួចដែលគេអាចប្រើប្រាស់បាន អ្នកខ្លះថាបើចង់បានសម្ភារៈដែលបន្សល់នៅក្នុងព្រលានត្រូវធ្វើការដោះដូរជាមួយពួកវៀតណាម ដូចជាគ្រឿងចក្រ ស៊ីម៉ង់ត៍ និងសម្ភារៈផ្សេងៗ។ ចំពោះបញ្ហាសម្ភារៈពុំមានភាពប្រាកដប្រជានិងច្បាស់លាស់ថាយ៉ាងមិចនោះឡើយ ។

ក្រោយពីខ្មែរក្រហមបានដួលរលំ ពួកគេបានបន្សល់ស្នាដៃដ៏គួឲ្យកោតស្ញប់ស្ញែងយ៉ាងច្រើននៅក្នុងការដ្ឋានព្រលានយន្តហោះដូចជាៈ

- ទ្រង់ទ្រាយរបស់ព្រលានយន្តហោះទាំងមូល
- ផ្ទៃដីសរុបចំនួន ១៤១៥ ហិកតា និងបរិវេនជុំវិញ ១៨ គីឡូម៉ែត្រ

[32] ហ៊ីង ស៊ុនតារា មេបញ្ជាការរងនៃកងទ័ពអាកាសកម្ពុជា ១៦ ០៨ ២០១៧

- អាគាររដ្ឋាបាលសរុប ១២ និងអាគារកំពស់ ៥ ជាន់
- ផ្លូវបេតុងប្រវែង ៥គីឡូម៉ែត
- រូងភ្នំ ដែលជាទីបញ្ជាការសម្ងាត់របស់ព្រលានយន្តហោះ «តារាជ»
- បាសាំងសម្រាប់ស្តុបប្រេងយន្តហោះចំនួន ៦ធ្វើពីបេតុង ហើយកបនៅតាមចង្កេះភ្នំ
- អាងស្តុបទឹកសម្រាប់ផ្គត់ផ្គង់ព្រលានយន្តហោះ
- របងព័ទ្ធជុំវិញព្រលានយន្តហោះ
- កន្លែងដាក់រ៉ាដាត្រួតពិនិត្យយន្តហោះនៅលើភ្នំក្រាំងដីរមាស
- ទីតាំងសម្រាប់លាក់យន្តហោះ។

## គ. ការវិលត្រឡប់មកវិញរបស់ប្រជាជន

ទឹកដីព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ គឺជាភូមិឋានដែលប្រជាជនរស់នៅ និងជាដីស្រែចំការដែលប្រជាជនធ្វើកសិកម្មអាស្រ័យផល ប៉ុន្តែមកដល់របបខ្មែរក្រហម តំបន់នេះត្រូវបានថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជាយកមកធ្វើជាទីតាំងដើម្បីកសាងព្រលានយន្តហោះថ្មី។ នៅក្រោយការដួលរលំនៃរបប ប៉ុល ពត ចាប់ពីឆ្នាំ១៩៧៩ ប្រជាជនមិនទាន់ចូលមកតាំងទីលំនៅ នៅលើទឹកដីព្រលានយន្តនោះទេ។ មកដល់ឆ្នាំ ១៩៨៣ ទើបមានវត្តមាននៃការចូលមកតាំងទីលំនៅរបស់ប្រជាជនជាបណ្តើរៗ ដោយសារតែទីនោះជាដីរបស់អ្នកភូមិពីមុនមកដែរ។ លោក ហ៊ីង ស៊ុនតារា មានប្រសាសន៍ថា ប្រជាជនចូលមកតាំងទីលំនៅជាច្រើននៅឆ្នាំ១៩៩៣ មានមូលហេតុខ្លះបណ្តាលមកពីការឃោសនាដើម្បីទាក់ទាញយកសន្លឹកឆ្នោតរបស់បណ្តាបក្សមួយចំនួន។ លោកបន្តទៀតថាមុនពេលដែលប្រជាជនចូលមករស់នៅ ព្រលានយន្តហោះមានរបងជុំវិញដែលកសាងបានប្រហែល ៧៥%ត្រូវបំផ្លាញទៅវិញ ដោយសារតែខ្វះខាតកម្លាំងសម្រាប់ការពារផងនោះ។

## ឃ. គម្រោងរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

យោងតាមប្រសាសន៍របស់សម្តេចតេជោហ៊ុន សែនកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១២ក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជា

ពលរដ្ឋចំនួន២៩៧គ្រួសារ ស្មើនឹង៧៣០ក្បាលដី មានផ្ទៃដី៣៦៩,៦៣ហិកតា រស់នៅភូមិអណ្តូងប្រេង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង[33] កន្លងទៅនោះបានឲ្យដឹងថារាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការសាងសង់ព្រលានយន្តហោះខ្នាតអន្តរជាតិមួយនៅខេត្តកំពង់ឆ្នាំង ដែលមានលទ្ធភាពអាចតភ្ជាប់ទំនាក់ទំនងជាមួយនឹងរាជធានីភ្នំពេញ បាននៅក្នុងឆ្នាំ២០២៥ ឬក៏ឆ្នាំ២០៣០ខាងមុខ ដោយប្រកាសកាត់ទុកផ្ទៃដីសរុបប្រមាណ១៤៦៣ហិកតា នៅតំបន់ចំណតយន្តហោះចាស់ក្នុងក្រុងកំពង់ឆ្នាំង ដើម្បីសាងសង់ព្រលានយន្តហោះថ្មី ដែលគ្រោងនឹងចំណាយថវិកាប្រមាណ១០០០លានដុល្លារទៅ២០០០លានដុល្លារអាមេរិក។[34] នាយករដ្ឋមន្ត្រីហ៊ុន សែន បានបន្តទៀតថាព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនឹងក្លាយជាអាកាសយានដ្ឋានអន្តរជាតិ នាពេលអនាគតដ៏ខ្លីខាងមុខនេះ។ ក្នុងហេតុផលនេះលោកនាយករដ្ឋមន្ត្រីបានប្រកាសបដិសេធផ្តល់កម្មសិទ្ធិដីធ្លីលើផ្ទៃដី៧៦៨ហិកតា ដែលប្រជាពលរដ្ឋកំពុងកាន់កាប់ និងទទួលផលពីរបរកសិកម្ម។ ជាមួយគ្នានេះដែរលោកបានអំពាវនាវមិនឲ្យប្រជាជនដែលកំពុងរស់នៅលើផ្ទៃដីអាកាសយានដ្ឋានខេត្តកំពង់ឆ្នាំងសាងសង់សំណង់រឹងនិងពង្រីកផ្ទៃដីកាន់កាប់បានទេតែគេមានសិទ្ធិអាស្រ័យផលពីផ្ទៃដីនោះរហូតដល់រដ្ឋត្រូវការ។

[33] មនោរម្យអាំងហ្វូ-ការសែតកោះសន្តិភាព 28 10 2012

[34] កម្ពុជាថ្មី-ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងជាមរតកដ៏មានតម្លៃជាប្រវត្តិសាស្ត្រ

# <u>ឯកសារយោង</u>

- ឯកសារ សាលាក្ដី
- អតីតទាហានខ្មែរក្រហមផ្ដល់សាក្ខីកម្មអំពីទារុណកម្មនៅព្រលានយន្តហោះ
- ទស្សនាវដ្ដីស្វែងរកការពិត លេខ២៥ ទំព័រ២៩ ដល់ ៣០
- Chinese stirs up ghosts of Khmer Rouge airport project
- The Cambodia Daily (Sleeping Giant)
- ណាយ៉ាន់ ចាន់ដា, សត្រូវបងប្អូនឯង,បកប្រែទេព ម៉េងឃាន
- ភ្នំពេញ), មជ្ឈមណ្ឌលឯកសារកម្ពុជា,២006
- កាសែត កម្ពុជាថ្មី-ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងជាមរតកដ៏មានតម្លៃជាប្រវត្តិសាស្ត្រ
- មនោរម្យអាំងហ្វូ-ការសែតកោះសន្តិភាព
- ហ៊ីង ស៊ុនតារា, មេបញ្ជាការរងនៃកងទ័ពអាកាសកម្ពុជា, ១៦ ០៨ ២០១៧
- អែម សុខឃីម,ទស្សនាវដ្ដីស្វែងរកការពិត, លេខ៥៥កញ្ញា២០០៤
- បញ្ជាការដ្ឋានកងទព័ជើងអាកាស, (មូលដ្ឋានទព័អាកាសកំពង់ឆ្នាំង). ប្រវត្តិសង្ខេបនៃព្រលានយន្តហោះកំពង់ឆ្នាំង
- អ.វ.ត.ក, *សុំណុំរឿង០០២,* ១៩កញ្ញា២០០៧-ECCC-OCIJ, លេខ/No: D427
- បទសម្ភាសន៍, សំ យ៉ុម ប្រជាជនមូលដ្ឋានៅភូមិក្រាំងលាវនាសម័យខ្មែរក្រហម, រសៀលថ្ងៃទី ១៦ សីហា ២០១៧
- អង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,សុំណុំរឿង០០២, ១៩កញ្ញា២០០៧-ECCC-OCIJ, លេខ/No: D427,ទំព័រ១៣១
- ហ៊ុល រស្មី, ២៣មិថុនា២០១៥, អតីតទាហានខ្មែរក្រហមផ្ដល់សក្ខីកម្មអពីទារុណកម្មនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង
- ឌី ខាំបូលី, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), លើកទី២ ២០១១,មជ្ឈមណ្ឌលឯកសារកម្ពុជា
- មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០២*, ទំនាក់ទនងចិន និងកម្ពុជាប្រជាធិបតេយ្យ.* ទស្សនាវដ្ដីស្វែងរកការពិតលេខ២៥. ទំព័រ២៩ដល់៣០

- លឿង គឹមធុង, *អតីតប្រជាជនធ្លាប់ចូលការដ្ឋាន*,អាយុ,កិច្ចសម្ភាសន៍ផ្ទាល់, ១៧សីហា១៧
- ឆេង វេង, *ទស្សនាវដ្តីស្វែងរកការពិត*, លេខ៥៥ , (កក្កដា, ២០០៤).ទំ១៤